# អរិយធម៌ក្រិចបុរាណ

ជនជាតិក្រិចបានមកតាំងទីរស់នៅប្រមាណជាង ៤០០០ឆ្នាំមុនគ.ស នៅតាមតំបន់សម្រុទ អេជី នៃមហាសមុទ្រមេឌីទ័រ៉ាណេ និងប្រមាណ ២៥០០ឆ្នាំមុនគ.ស[១] ក្រិចបានក្លាយជាអាណាចក្រដ៏ធំមួយដែលមានផ្ទៃដី លាតសន្ធឹងពីប្រទេសអេស្ប៉ាញ រហូតដល់ប្រទេសឥណ្ឌា ក្នុងអំឡុងពេលការដឹកនាំរបស់ស្តេច អេឡេញសេនឌ័រ (Alexander the great)។[២]

មនុស្សក្នុងអរិយធម៌ក្រិចពូកែខាងនយោបាយ យោធា និងវប្បធម៌ ដែលធ្វើឱ្យអាណាចក្រមួយនេះមានការរីកចម្រើនយ៉ាងខ្លាំងនៅក្នុងតំបន់អឺរ៉ុប។ ផ្ទុយពីអាណាចក្រធំៗផ្សេងទៀតដែលមានស្តេចធ្វើការបង្រួបបង្រួមគ្នា ដោយអាណាចក្រក្រិច គឺកើតឡើងពីរដ្ឋឯករាជ្យតូចៗប្រមាណជាង ១០០០រដ្ឋ (City-states) រួមបញ្ចូលគ្នា[៣] ដើម្បីបង្កើតបានជាអាណាចក្រក្រិចដ៏ធំមួយ។ ចំពោះរដ្ឋបាលរដ្ឋទាំង១០០០នោះ គឺមានការគ្រប់គ្រង និងការកំណត់ច្បាប់រៀងៗខ្លួន។ ក្នុងចំណោមនោះរដ្ឋសំខាន់ៗមានពីរ គឺ Athénes និង Sparte។ មុននៃការបង្រួបបង្រួមគ្នារដ្ឋទាំងនោះតែងតែធ្វើសង្គ្រាមរវាងគ្នាទៅវិញទៅមក។ Athénes បានក្លាយជារាជធានីនៃអាណាចក្រក្រិច ដែលនៅទីនោះមានការបង្កើតលទ្ធិប្រជាធិបតេយ្យដំបូង ហើយលទ្ធិប្រជាធិបតេយ្យនោះ គឺជាផ្នែកមួយនៃការជួយពង្រឹង និងគ្រប់គ្រងអំណាចរបស់ខ្លួន។ មនុស្សក្រិចពូកែខាងផ្នែកនយោបាយ និងយោធា ដូច្នេះហើយបានធ្វើឱ្យអាណាចក្រមួយនេះ បានពង្រីកខ្លួនគ្រប់គ្រងលើរដ្ឋដ៏ទៃទៀត និងការពារខ្លួនពីការឈ្លានពានពីរដ្ឋផ្សេងទៀត ជាពិសេសពីសំណាក់អាណាចក្រពែក។[៤]

នៅពេលមានសង្គ្រាមម្តងៗ ពួកគេកៀរគរប្រជាជនមកការពារប្រជាជាតិរបស់ពួកគេ។ ប្រជាជនក្រិចមានមោទនភាពលើទាហានដ៏អង់អាច ក្លាហានដែលពួកគេចាត់ទុកថាជាវីរៈ

---

[១] www.bbc.com: Ancient Greece

[២] www.britannica.com: ancient-Greece

[៣] *ibid*

[៤] www.histoirepourtous.fr : grace-antique

អត្ថបទដោយ៖ អេង តុលា

បុរសរបស់ពួកគេក្នុងការការពារទឹកដី ។ សកម្មភាពនៃភាពក្លាហានរបស់ពួកគេបានក្លាយជារឿងព្រេងនៅជំនាន់ក្រោយ និងបានតែងជាកំណាព្យដើម្បីលើកដម្កើន ដល់ទាហានរបស់ពួកគេ។ នៅឆ្នាំ ៧៧៦[៥]មុនគ.ស.គំនិតនៃការលើកដម្កើននេះក៏បានក្លាយជាកីឡាអូឡាំពិកដើម្បីប្រកួតប្រជែងសមត្ថភាព កំលាំងកាយសម្បទា និងប្រាជ្ញារបស់ពួកគេនៅទីក្រុង Olympia។[៦] ស្នាដៃទាំងអស់ដែលបន្សល់ពីក្រិចបុរាណដូចជា សិល្បៈ វប្បធម៌ ទស្សនៈវិជ្ជា និងសំណង់ស្ថាបត្យកម្មក្រិចដ៏ល្អវិចិត្រ គឺជាការបង្ហាញពីអត្តសញ្ញាណមួយនៃលោកខាងលិច។ ជាពិសេសរូបចម្លាក់ដ៏ល្បីល្បាញជាច្រើន ដែលបានដាក់តាំងបង្ហាញនៅតាមសារមន្ទីរធំៗលើពិភពលោក។ អត្តសញ្ញាណនៃសិល្បៈក្រិចបុរាណ គឺជាការបង្ហាញតាមរយៈសសរសំខាន់ៗនៅតាមប្រាសាទ វិហារ នឹងសំណង់សាធារណៈផ្សេងៗនិងបានបែងចែកចេញជា៣រចនាបថមានដូចជា រចនាបថ Doric Ionic និង Corinthian។[៧] សាសនាដែលរួមបញ្ចូលនូវទេវកថាជាច្រើនបានជះឥទ្ធិពលទៅលើវប្បធម៌ប្រទេសផ្សេងៗទៀត ឧទា. ប្រទេសប៉ាគីស្ថាន[៨] និងជាពិសេសបានជះឥទ្ធិពលខ្លាំងលើសិល្បៈរ៉ូមាំងសម័យបុរាណ។

អ្នកទស្សនៈវិទូក្រិចដែលសិក្សាលើ សីលធម៌ ច្បាប់ធម្មជាតិនៃការរស់នៅមានតួនាទីក្នុងការជួយការងារនយោបាយ និងការគ្រប់គ្រងលើអាណាចក្ររបស់ខ្លួន។ បើនិយាយពីភាសាវិញ ភាសាក្រិចក៏បានជះឥទ្ធិពលគួរឱ្យគត់សម្គាល់ដែរនៅតំបន់អ៊ឺរ៉ុប។ អរិយធម៌នេះមានអាយុកាលជាង ២៥០០ឆ្នាំ មុនគ.ស. ហើយក៏ជាមូលដ្ឋានគ្រឹះនៃភាសាទំនើបជាច្រើនទៀតដែរ ជាពិសេសភាសាបារាំង ដែលខ្ចីពាក្យឫសពីភាសាក្រិចយកមកប្រើប្រាស់រហូតដល់សព្វថ្ងៃនេះ។

ជារួមអរិយធម៌និងអាណាចក្រក្រិច គឺមានភាពរុងរឿងខ្លាំងក្នុងតំបន់អឺរ៉ុបទាំងធនធានមនុស្ស សិល្បៈ វិប្បធម៌ សាសនា និងសំណង់ស្ថាបត្យកម្មដ៏ល្អឯកដែលបង្ហាញតាមប្រាសាទ

---

[៥] www.olympics.com : Ancient-olympic-games,

[៦] www.britannica.com: Ancient Greece,

[៧] www. architecture competitions: Three column type of ancient Greece

[៨] រូបបដិមាព្រះពុទ្ធ(Greco-Buddhist)ដំបូងគេនៅ តំបន់Gandhara

អត្ថបទដោយ៖ អេង តុលា

វិហារ នឹងសំណង់សាធារណៈផ្សេងៗ។ បើទោះជាអាណាចក្រនេះបានដួលរលំក៏ពិតមែន តែពល់ស្នាដៃរបស់ខ្លួនបានក្លាយជាមូលដ្ឋានគ្រឹះ នៃបេតិកភណ្ឌក្នុងតំបន់អ៊ឺរ៉ុប នឹងជាប្រវត្តិសាស្ត្រ នៃអរិយធម៌ដំបូងមួយក្នុងចំណោមអរិយធម៌ដ៏ទៃទៀតនៅលើពិភពលោក។




រូបលេខ១៖ ផែនទីក្រិចបុរាណ

ប្រភព៖ Printerest

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៖ ទីក្រុង Acropolis
ប្រភព៖ Greeceancient.com



រូបលេខ៣៖ ប្រាសាទ អូឡាំពិក

ប្រភព៖ Greeceancient.com

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៨៖ បដិមាក្រិចបុរាណ(Laocoön and His Sons )

ប្រភព៖https://commons.wikimedia.org/



រូបលេខ២៩៖ ភាជន៍ដែលគំនូរបង្ហាញអំពីការធ្វើចម្បាំង

ប្រភព៖https://commons.wikimedia.org/

អត្ថបទដោយ៖ អេង តុលា



រូបលេខ៧៖ ចម្លាក់បង្ហាញអំពីកីឡាអូឡាំពិក
ប្រភព៖Printerest



រូបលេខ៨៖ សសរចនាបទ
Corinthien
ប្រភព៖ Metropolitan museum

អត្ថបទដោយ៖ អេង តុលា



រូបលេខ៨៖ កីឡាដ្ឋានមួយ Acropolis of Athens

ប្រភព៖ SPQR

## ឯកសារយោង

www.bbc.com: Ancient Greece,
www.britannica.com: Ancient-Greece,
www.histoirepourtous.fr : Grac-antique,
www.olympics.com: Ancient-olympic-games,
www.architecture competitions: Three column type of ancient Greece,

អត្ថបទដោយ៖ អេង តុលា